# គោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរ

### *តើអ្វីទៅជាគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរ ?*

STREAM គោលការណ៍អនុវត្តឱ្យកាន់តែប្រសើរ (BPGs) តម្រង់ទិសដើម្បីផ្លាស់ប្តូរនូវរាល់មេរៀនដែលបានរៀនសូត្រពីការងារអនុវត្តនៅតាមមូលដ្ឋាន ឬបទពិសោធន៍ដែលទទួលបានតាមរយៈការងារស្រាវជ្រាវនៅអាស៊ីប៉ាស៊ីហ្វិច ។ បទពិសោធន៍ទាំងនោះនឹងជួយដល់ប្រជាជន ស្ថាប័ន និង អ្នកបង្កើតគោលនយោបាយ ដើម្បីប្រើប្រាស់វាធ្វើជាយន្តការ និង ឧបករណ៍ថ្មីៗ សម្រាប់ជាជំនួយដល់ការគ្រប់គ្រងធនធានវារីជាតឱ្យបានត្រឹមត្រូវ និង លើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ។

### *តើហេតុអ្វីចាំបាច់មានគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរ ?*

គោលការណ៍អនុវត្តឱ្យកាន់តែប្រសើរគឺមានប្រយោជន៍ណាស់ដើម្បីជួយធ្វើឱ្យកាន់តែប្រសើរឡើងនូវរបៀបបំពេញការងាររបស់ពួកយើង (ចំណេះដឹង ជំនាញ សមត្ថភាព និង ការអនុវត្ត) ។

### *តើគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរបង្កើតឡើងសម្រាប់នរណា ?*

គោលការណ៍អនុវត្តឱ្យកាន់តែប្រសើរ គឺបង្កើតឡើងដើម្បីឱ្យអ្នកពាក់ព័ន្ធមួយចំនួនប្រើប្រាស់ :

- មន្ត្រីផ្សព្វផ្សាយ
- មន្ត្រីមូលដ្ឋាន
- អ្នករៀបចំសហគមន៍

} ធ្វើការជាមួយប្រជាជនក្រីក្រដោយផ្ទាល់

- ប្រធានក្រុមតាមភូមិ *Jankars*[1] (មេក្រុមដឹកនាំក្រុមជួយខ្លួនឯងនៅប្រទេសឥណ្ឌា)
- ក្រុមជួយដោយខ្លួនឯង
- អង្គការក្រៅរដ្ឋាភិបាល
- ស្ថាប័នរដ្ឋាភិបាល
- ក្រុមអ្នកផ្តល់ជំនួយ
- ស្ថាប័នដ៏ទៃទៀតដែលយល់ថា គោលការណ៍អនុវត្តឱ្យកាន់តែប្រសើរ គឺមានប្រយោជន៍ដល់ពួកគាត់

### *តើហេតុអ្វីបានជាយើងប្រើពាក្យ "ប្រសើរជាង" ម៉េចមិនព្រមប្រើពាក្យ "ល្អបំផុត" ?*

តាមរយៈការខិតខំសម្រេចឱ្យបាន "ការអនុវត្តឱ្យល្អបំផុត" នាំឱ្យយើងចំណេញបាននូវចំណេះដឹងថ្មីៗ បង្កើនជំនាញបន្ថែម និង ជួនកាល អាចរកឃើញនូវគំរិយាបទថ្មីៗ និង ល្អៗទៀតផង ។ តាមបទពិសោធន៍មេរៀនដូចបានរៀបរាប់ និង មានប្រយោជន៍រួមគ្នា យើងសង្ឃឹមថាវានឹងផ្តល់នូវគោលការណ៍សម្រាប់ *"ការអនុវត្តឱ្យបានកាន់តែប្រសើរឡើង"*។

### *តើនរណាជាអ្នកបង្កើតគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរ ?*

គោលការណ៍អនុវត្តឱ្យកាន់តែប្រសើរ អាចធ្វើការកែលំអដោយអ្នកដែលមានបទពិសោធន៍ ដើម្បីចែករំលែកនូវរាល់បទពិសោធន៍ទាំងអស់នោះដល់កសិករ អ្នកនេសាទ អ្នកពាក់ព័ន្ធ-នឹងសកម្មភាពនេសាទ ជំនាញការ ។ គ្រប់ដំណើរការត្រូវបានសម្របសម្រួលដោយ the STREAM Initiative.

### *តើខ្ញុំអាចរកបានគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរនៅទីកន្លែងណា ?*

គោលការណ៍អនុវត្ត អាចស្វែងរកបានតាមរយៈមជ្ឈមណ្ឌលទំនាក់ទំនង (STREAM Communications Hubs) ជាភាសាជាតិ ឬពីការិយាល័យតំបន់របស់ STREAM នៅទីក្រុងបាងកក ប្រទេស ថៃឡង់ដ៏ ឬពីគេហទំព័រ http://www.streaminitiative.org/Library/bpg/index.html

### *តើយោបល់របស់អ្នក...*

តើអស់លោកអ្នកមានអ្វីដែលត្រូវការស្វែងយល់បន្ថែមអំពីយើងដែរឬទេ? តើអស់លោកអ្នកមានអ្វីដែលជាមតិយោបល់ជួយដល់យើង? ប្រសិនបើ អស់លោកអ្នកត្រូវការនូវព័ត៌មានអ្វី សូមទាក់ទងមជ្ឈមណ្ឌល STREAM នៅតាមប្រទេសរបស់អល់លោកអ្នក ។

---

(មេក្រុមដឹកនាំក្រុមជួយខ្លួនឯងនៅប្រទេសឥណ្ឌា)